00702275

E50/2/1/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 06 / 2011
ម៉ោង (Time/Heure) : 12:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក(០១/០២)
Case File/Dossier N°. 002/19-09-2007-ECCC/SC(01/02)

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA-MILART**
ចៅក្រម ស៊ិន វិទ្ធ
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ:

# សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ E50/2/1/4

---

**ជនជាប់ចោទ**

នួន ជា

អៀង ធីរិទ្ធ

**មេធាវីការពារក្ដីជនជាប់ចោទ**

**នួន ជា**

សុន អរុណ

Michiel PESTMAN

Victor KOPPE

**មេធាវីការពារក្ដីជនជាប់ចោទ**

**អៀង ធីរិទ្ធ**

ផាត់ ពៅសឹង

កញ្ញា Diana ELLIS, QC

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើម**

**បណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMMONEAU-FORT

*សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង*

*លើសំណើសុំដោះលែងជាបន្ទាន់ ។*

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្តឹងសាទុក្ខភ្លាមៗ ដាក់ដោយសហមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា (“ជនជាប់ចោទ”) ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើសុំ ដោះលែងជាបន្ទាន់។

## ១. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយរបស់ខ្លួនក្នុងសំណុំរឿង០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក (“សំណុំរឿង០០២”) ដែលនៅក្នុងដីកានោះ សហចៅក្រមស៊ើបអង្កេត បានបង្គាប់ថា ជនជាប់ចោទ ត្រូវរក្សាទុកក្នុងឃុំបណ្តោះអាសន្នរហូតដល់ពេលត្រូវនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។ អង្គបុរេជំនុំជម្រះ បានទទួលសំណុំរឿងនេះ បន្ទាប់ពីការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[2] និងសារណាបណ្តឹងឧទ្ធរណ៍[3]ប្រឆាំងនឹងដីកាដំណោះស្រាយដែលបានដាក់ដោយជនជាប់ចោទ (ដែលហៅថា “បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ”)។

២. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចរបស់ខ្លួនមិនទាន់មានសំអាងហេតុស្តីពីបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ប្រឆាំងនឹងដីកាដំណោះស្រាយ (“ផ្នែកសម្រេចសេចក្តី”) ដោយធ្វើការបញ្ជាក់ថា សំអាងហេតុ នឹងចេញនៅពេលក្រោយតាមពេលវេលាសមស្រប[4]។ ផ្នែកសម្រេចសេចក្តី បានសម្រេចតំកល់ដីកាដំណោះស្រាយមួយផ្នែក និងបានកែប្រែមួយផ្នែក។ ផ្នែកសម្រេចសេចក្តីនេះ បង្គាប់ឲ្យរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នរហូត

---

[1] D427 កថាខណ្ឌ១៦២២-១៦២៤ និងទំព័រ៤០២ (“ដីកាដំណោះស្រាយ”)។ ដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។

[2] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (នួន ជា) D427/3 ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០, អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, D427/3 ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។

[3] បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (នួន ជា) D427/3/1 ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ លើដីកាដំណោះស្រាយ D427/2/1 ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។

[4] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខរបស់អៀង ធីរិទ្ធ និងនួន ជាប្រឆាំងនឹងដីកាដំណោះស្រាយ D427/[illegible], ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ទំព័រ៧។

00702278



ដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[5]។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសំអាងហេតុរបស់ខ្លួនលើចំណុចស្ដីពីការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នដែលសម្រេចក្នុងផ្នែកសម្រេចសេចក្ដី[6] ហើយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសំអាងហេតុរបស់ខ្លួនលើចំណុចសេសសល់ដែលមានក្នុងផ្នែកសម្រេចសេចក្ដីនេះ[7]។

៣. នៅថ្ងៃទី១៨ និង២១ ខែមករា ឆ្នាំ២០១១ នួន ជា និងអៀង ធីរិទ្ធ បានដាក់សំណើសុំដោះលែងជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង[8] និងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្ដីសម្រេចរបស់ខ្លួនដោយបដិសេធសំណើសុំដោះលែង(“សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង”)[9]។ នៅថ្ងៃទី០១ និង០២ ខែមីនា ឆ្នាំ២០១១ នួន ជា និង អៀង ធីរិទ្ធ បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខជាបន្តបន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[10]។ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១ ជនជាប់ចោទ បានដាក់សារណាបណ្ដឹងសាទុក្ខ (ដែលហៅថា “សារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ” រួមមាន “សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា” និង“សារណាបណ្ដឹងសាទុក្ខរបស់ អៀង ធីរិទ្ធ”)[11]។ សហព្រះរាជអាជ្ញា បានដាក់សារណាតបទៅនឹងសារណារបស់ អៀង

---

[5] ផ្នែកសម្រេចសេចក្ដី ទំព័រ៧។

[6] សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខរបស់អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយៈ សំអាងហេតុសំរាប់ការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន D427/2/13 ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។

[7] សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខរបស់ នួន ជា និង អៀង ធីរិទ្ធប្រឆាំងនឹងដីកាដំណោះស្រាយ D427/2/15, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១។

[8] សំណើសុំដោះលែងភ្លាមៗរបស់ នួន ជា E19, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១។ សំណើសុំដោះលែងភ្លាមៗរបស់លោកស្រី អៀង ធីរិទ្ធ E21, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។

[9] សេចក្ដីសម្រេចស្ដីពីសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ E50, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១។

[10] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ E50/2 ថ្ងៃទី២ ខែមីនា ឆ្នាំ២០១១។

[11] បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ(នួន ជា) E50/1/1/1 ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១។ បណ្ដឹងសាទុក្ខប្រឆាំងនឹង“សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើ *សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់។*

00702279



ធីរិទ្ធ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១[12] និងសារណារបស់ នួន ជា នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ (ដែលហៅថា "សារណាតប" រួមមាន "សារណាតបទៅនឹង អៀង ធីរិទ្ធ" និង"សារណាតបទៅនឹងនួន ជា")[13]។ នួន ជា និង អៀង ធីរិទ្ធ បានដាក់ការឆ្លើយតបទៅនឹងសារណាតបរៀងៗខ្លួន នៅថ្ងៃទី០៤ និង០៥ ខែមេសា ឆ្នាំ២០១១ (រួមមាន "ការឆ្លើយតបរបស់ នួន ជា " និង "ការឆ្លើយតបរបស់ អៀង ធីរិទ្ធ")[14]។

៤. អនុលោមតាមវិធាន១០៨(៤)នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី៧) អង្គជំនុំជម្រះតុលាការកំពូលត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទប្រឆាំងនឹងការឃុំខ្លួនឱ្យបានឆាប់ដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ មិនឱ្យលើសពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ដែលមានរយៈពេលបីខែ បន្ទាប់ពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ទទួលបានសំណុំរឿងនៃបណ្ដឹងសាទុក្ខ[15]។

---

សុំដោះលែងជាបន្ទាន់របស់នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ" ដែលបានដាក់នូវដោយភាគីបណ្ដឹងសាទុក្ខ លោកស្រី អៀង ធីរិទ្ធ, E50/2/1/1 នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១។

[12] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបសអៀង ធីរិទ្ធប្រឆាំងនឹង"សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើសុំដោះលែងជាបន្ទាន់របស់នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ" E50/2/1/2 នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ("សារណាតប")។

[13] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីសំណើសុំដោះលែងបន្ទាន់របស់នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ E50/2/1/2 នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១។

[14] ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង ធីរិទ្ធប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើសុំដោះលែងជាបន្ទាន់របស់នួន ជា ខៀវ សំផន និងអៀង សារី E50/2/1/3, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១។ ការឆ្លើយតបទៅនឹងសារណាតបសហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសំណើសុំដោះលែងជាបន្ទាន់របស់នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ E50/2/1/3 ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១។

[15] វិធាន១០៥(២)នៃវិធានផ្ទៃក្នុងមិនបានតម្រូវឱ្យមាននូវសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដែលផ្ទុយពីវិធាន១០៥(៣)នៃវិធានផ្ទៃក្នុង ដូច្នេះ ពាក្យ "សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ" ក្នុងវិធាន១០៨(៤) មិនអាចយោងទៅលើបណ្ដឹងសាទុក្ខដែលដែលជនជាប់ចោទ បានដាក់នៅថ្ងៃទី១ និង ២ ខែមីនា ឆ្នាំ២០១១។ ក្នុងឯកសារជាភាសាខ្មែរនៃវិធាន១០៨(៤)នៃវិធានផ្ទៃក្នុង កាលបរិច្ឆេទរយៈពេលបីខែ គិតចាប់ពីពេលទទួលបាននូវ"សំណុំរឿង"។ ហេតុដូច្នេះ អង្គជំនុំជម្រះតុ[illegible] កាលបរិច្ឆេទរយៈពេលបីខែក្នុងវិធាន១០៨(៤)នៃវិធានផ្ទៃក្នុង គិតចាប់ពីថ្ងៃជូនដំណឹងអំពីទ[illegible] ជនជាប់ចោទ ដែលដាក់នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១។ រយៈពេលបីខែបន្ទាប់ពីថ្ងៃទី០៤ ខែមី[illegible] *សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេ[illegible] លើសំណើសុំដោះលែងជាបន្ទាន់*។

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

## ២. សារណា

### ២.១ សារណានៃបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ

#### ២.១.១ ឧទ្ទេសករណ៍បណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ

៥. អៀង ធីរិទ្ធ ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលនូវការយល់ឃើញនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយសម្រេចជំនួសវិញ៖

ក. ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមានសំអាងហេតុគ្រប់គ្រាន់

ខ. លុបចោលសេចក្តីថ្លែងការណ៍ខាងក្រោមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសេចក្តីសម្រេចរបស់ខ្លួន ដែលថា“ សហចៅក្រមស៊ើបអង្កេត បានកត់សំគាល់ឃើញថា អៀង ធីរិទ្ធ មានធនធានគ្រប់គ្រាន់ ដែលអាចសម្រួលដល់ការរត់គេចខ្លួនទៅកាន់ប្រទេសដទៃទៀត និងថា ជនជាប់ចោទអាចនឹងព្យាយាមរត់គេចពីដំណើរការ ស្វែងរកយុត្តិធម៌ដោយជនជាប់ចោទយល់ឃើញថា គាត់អាចនឹងត្រូវប្រឈមមុខនឹងការផ្តន្ទាទោសធ្ងន់ធ្ងរ ក្នុងករណីដែលតុលាការរកឃើញថាគាត់មានពិរុទ្ធ”។

គ. ថាជនជាប់ចោទ ត្រូវបានឃុំខ្លួនខុសច្បាប់ ចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ និង

ឃ. ថា ការឃុំខ្លួនខុសច្បាប់នោះ ត្រូវតែទូទាត់សងនៅដំណាក់កាលផ្តន្ទាទោស[16]។

៦. នៅក្នុងការគាំទ្រលើសំណើនេះ អៀង ធីរិទ្ធ លើកឡើងនូវឧទ្ទេសករណ៍បណ្តឹងសាទុក្ខចំនួនបីនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនដូចខាងក្រោមៈ

---

ខែមិថុនា ឆ្នាំ២០១១។ ដោយអនុលោមតាមវិធាន៣៩(៣)នៃវិធានផ្ទៃក្នុង ដោយហេតុថារយៈ[illegible]ផុតនៅថ្ងៃ[illegible] រយៈពេលកំណត់ត្រូវពន្យារដោយស្វ័យប្រវត្តិដល់ថ្ងៃច័ន្ទ គឺថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

[16] សារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣១។

*សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់។*

### ២.១.១.១ កំហុសឆ្គងនៃអង្គច្បាប់ - ការខកខានមិនបានលើកពីទឡ្ហីករណ៍របស់ អៀង ធីរិទ្ធ

៧. អៀង ធីរិទ្ធ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាលើ "ទឡ្ហីករណ៍សំខាន់" របស់ខ្លួននៅអង្គជំនុំជម្រះសាលាដំបូង ដែលថាផ្នែកសម្រេចសេចក្តី មិនមានលក្ខណៈសម្បត្តិជា "សេចក្តីសម្រេច" នោះទេ ដោយសារតែពុំមានសំអាងហេតុ ដោយអនុលោមតាមវិធាន៧៧(១៤) នៃវិធានផ្ទៃក្នុង។ ជាលទ្ធផល មូលដ្ឋានផ្លូវច្បាប់សម្រាប់ការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន នឹងត្រូវអស់សុពលភាពជាស្វ័យប្រវត្តិ ដោយសារការខកខានរបស់អង្គបុរេជំនុំជម្រះមិនបានចេញនូវសេចក្តីសម្រេចមួយដែលមានសុពលភាពក្នុងរយៈពេលកំណត់ ដែលផុតកំណត់ក្នុងរយៈពេលបួនខែ តាមវិធាន៦៨(២)(៣)នៃវិធានផ្ទៃក្នុង។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានលើកឡើងពីទឡ្ហីករណ៍សំខាន់នេះ គឺជាការប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[17]។

### ២.១.១.២ កំហុសឆ្គងនៃអង្គច្បាប់ - ការបកស្រាយមិនត្រឹមត្រូវនៃវិធាន ៦៨(២)និង (៣)នៃវិធានផ្ទៃក្នុង

៨. អៀង ធីរិទ្ធ ជំទាស់ថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសឆ្គងនៃអង្គច្បាប់ដោយភាន់ច្រឡំក្នុងការបកស្រាយលើវិធាន៦៨នៃវិធានផ្ទៃក្នុង។ អៀង ធីរិទ្ធ លើកឡើងថា គ្មានមូលដ្ឋានគតិយុត្តណាមួយដែលគេអាចយកមកធ្វើជាសំអាងដើម្បីរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ឡើយ ដែលបានផុតកំណត់ "យ៉ាងយូរបំផុត" នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១[18](គឺមានរយៈពេលបួនខែ និងមួយថ្ងៃក្រោយពីថ្ងៃដាក់ និងថ្ងៃជូនដំណឹងនៃសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ) ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ (គឺជាកាលបរិច្ឆេទនៃការចេញសំអាងហេតុរបស់អង្គបុរេជំនុំជម្រះលើចំណុចដែលមិនមែនជាការរក្សាទុកជនជាប់ចោទក្នុងឃុំនៃផ្នែកសម្រេចសេចក្តីរបស់ខ្លួន)[19]។ នៅពេលដែលអង្គជំនុំជម្រះ

---

[17] សារណាបណ្តឹងសាទុក្ខរបស់អៀង ធីរិទ្ធ កថាខណ្ឌ១២-១៤។

[18] សារណាបណ្តឹងសាទុក្ខរបស់អៀង ធីរិទ្ធ កថាខណ្ឌ៥-១៣។

[19] សារណាបណ្តឹងសាទុក្ខរបស់អៀង ធីរិទ្ធ កថាខណ្ឌ១៩-២៥។

00702282



សាលាដំបូង ទទួលស្គាល់ថាមានវិការៈផ្នែកនីតិវិធីនៅក្នុងការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការចេញនូវសំអាងហេតុក្នុងរយៈពេលកំណត់បួនខែដូចដែលមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុងនោះ អៀង ធីរិទ្ធ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនទទួលស្គាល់សេចក្ដីសន្និដ្ឋានដែលមានតែមួយគត់ នោះគឺថា ការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នក្នុងរយៈពេលចន្លោះពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ និងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ គឺខុសច្បាប់[20]។

### ២.១.១.៣ កំហុសឆ្គងនៃអង្គហេតុ - ការយល់ឃើញមិនត្រឹមត្រូវពីដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត

៩. កំហុសឆ្គងនៃអង្គហេតុដែលបានលើកឡើងដោយ អៀង ធីរិទ្ធ គឺមានការទាក់ទងទៅនឹងទឡ្ហីករណ៍សម្រាប់ការឃុំខ្លួនដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង។ ក្នុងការពិភាក្សាលើការអនុវត្តនូវលក្ខខណ្ឌតម្រូវនៃវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង អៀង ធីរិទ្ធ លើកឡើងថា សេចក្ដីថ្លែងការណ៍ខាងក្រោមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ជាក់ស្ដែងណាស់ មិនមានលក្ខណៈត្រឹមត្រូវ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌: " សហចៅក្រមស៊ើបអង្កេត បានកត់សំគាល់ឃើញថា អៀង ធីរិទ្ធ មានធនធានគ្រប់គ្រាន់ដែលអាចសម្រួលដល់ការរត់គេចខ្លួនទៅប្រទេសមួយផ្សេងទៀត ហើយថា ជនជាប់ចោទ នឹងអាចព្យាយាមរត់គេចពីដំណើរស្វែងរកយុត្តិធម៌ដែលជនជាប់ចោទនឹងត្រូវប្រឈមមុខក្នុងករណីដែលមានការផ្ដន្ទាទោស"[21]។ យោងតាម អៀង ធីរិទ្ធ បានឱ្យដឹងថា ដីកា[22] ដែលអង្គជំនុំជម្រះសាលាដំបូងយោងនោះ មិនមានសេចក្ដីថ្លែងការណ៍បែបនេះទេ ហើយយោងតាមព័ត៌មាននៅក្នុងសំណុំរឿងនោះ បង្ហាញថា ជនជាប់ចោទជាជនក្រីក្រ [23]។

### ២.១.២ សារណាតបរបស់សហព្រះរាជអាជ្ញានៅនឹង អៀង ធីរិទ្ធ

---

[20] សារណាបណ្ដឹងសាទុក្ខរបស់អៀង ធីរិទ្ធ កថាខណ្ឌ២៥។

[21] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៤១។ សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៦-២៧។

[22] C20/8។

[23] សារណាបណ្ដឹងសាទុក្ខរបស់អៀង ធីរិទ្ធ កថាខណ្ឌ២៦-២៨។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

១០. នៅក្នុងសារណាតបរបស់ខ្លួនទៅនឹង អៀង ធីរិទ្ធ សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលនូវបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាំងស្រុង។ សហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទ ខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង ប្រព្រឹត្តនូវកំហុសឆ្គង ដែលស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការដោះស្រាយលើទឡ្ហីករណ៍របស់ជនជាប់ចោទ ក្នុងការធ្វើសេចក្តីសន្និដ្ឋានថាជាសំណាងសមស្រប និងក្នុងការបង្ហាញនូវការយល់ឃើញនៃដីកាដំណោះស្រាយ។ សហព្រះរាជអាជ្ញាលើកឡើងនូវទឡ្ហីករណ៍ដូចខាងក្រោម៖

### ២.១.២.១ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងគ្រប់គ្រាន់លើទឡ្ហីករណ៍របស់ អៀង ធីរិទ្ធ

១១. សហព្រះរាជអាជ្ញាបានលើកឡើងថា អៀង ធីរិទ្ធ ខកខានពុំបានពន្យល់ ថាតើទឡ្ហីករណ៍របស់ខ្លួនស្តីពីការបកស្រាយវិធាន៦៨នៃវិធានផ្ទៃក្នុង ខុសប្លែកដូចម្តេចឡើយ ពីទឡ្ហីករណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបលម្អិតនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ[24]។ អង្គជំនុំជម្រះសាលាដំបូង បានបំពេញកាតព្វកិច្ចរបស់ខ្លួនយ៉ាងគ្រប់ជ្រុងជ្រោយក្នុងការផ្តល់នូវសំអាងហេតុលើបញ្ហាអង្គច្បាប់នានា។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូង បានលើកយកយុត្តិសាស្ត្រអន្តរជាតិមកធ្វើជាសំអាងដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ទោះបីជាអង្គបុរេជំនុំជម្រះបានប្រព្រឹត្តវិការៈផ្នែកនីតិវិធីក៏ដោយ ក៏វិការៈនេះ មិនបានធ្វើឱ្យការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នអស់សុពលភាពគតិយុត្ត និងមិនតម្រូវឱ្យមានការទូទាត់ដោយដោះលែងជាបន្ទាន់នោះឡើយ[25]។

---

[24] សារណាតបទៅនឹងអៀង ធីរិទ្ធ កថាខណ្ឌ៦ យោងលើកថាខណ្ឌ២៣៣៦ និង៤៣នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

[25] សារណាតបទៅនឹងអៀង ធីរិទ្ធកថាខណ្ឌ៧។

### ២.១.២.២ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការចូលទាត់មានហេតុផលត្រឹមត្រូវ និងស្ថិតក្នុងក្របខណ្ឌនៃឆន្ទានុសិទ្ធិរបស់ខ្លួន

១២. សហព្រះរាជអាជ្ញា លើកឡើងថា ការបញ្ជាក់អះអាងរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសុពលភាពគតិយុត្តនៃផ្នែកសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះមានបង្អែកយ៉ាងរឹងមាំដោយយុត្តិសាស្ត្រដែលត្រូវបានលើកឡើងនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដូចជាយុត្តិសាស្ត្រដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងពេលសវនាការស្ដីពីការរក្សាទុកជនជាប់ចោទក្នុងឃុំ រាប់ទាំងរឿងក្ដីនៃ*រដ្ឋអាជ្ញា ទល់នឹង Popovic*[26]ផង។ លើសពីនេះទៀត អៀង ធីរិទ្ធ ពុំបានលើកឡើងអំពីផលប៉ះពាល់ណាមួយរបស់ខ្លួននៅពេលបច្ចុប្បន្នដែលបណ្ដាលមកពីវិការៈផ្នែកនីតិវិធី របស់អង្គបុរេជំនុំជម្រះឡើយ ហើយបញ្ហាដោះស្រាយសំណងដែលសមស្រប ចំពោះវិការៈផ្នែកនីតិវិធីនេះ នឹងត្រូវដោះស្រាយនៅពេលចុងបញ្ចប់នៃការជំនុំជម្រះ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច និងស្របជាមួយយុត្តិសាស្ត្រអន្តរជាតិផងដែរ[27]។

### ២.១.២.៣ អង្គជំនុំជម្រះសាលាដំបូង បកស្រាយដោយត្រឹមត្រូវនូវសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងលទ្ធភាពឧបាទានរបស់ អៀង ធីរិទ្ធ

១៣. សហព្រះរាជអាជ្ញា អះអាងថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលអង្គជំនុំជម្រះសាលាដំបូង បានលើកយកមកសំអាងក្នុងសេចក្ដីសម្រេចរបស់ខ្លួននោះ គាំទ្រដល់សេចក្ដីបញ្ជាក់

[26] សារណាតបទៅនឹងអៀង ធីរិទ្ធកថាខណ្ឌ ៩-១០ យោងរឿងក្ដី *Prosecutor v. Popović*។ សេចក្ដីសម្រេចស្ដីពីបណ្ដឹងឧទ្ធរណ៍នៃសេចក្ដីសម្រេចអង្គជំនុំជម្រះសាលាដំបូង បដិសេធការដោះលែង Ljubomir Borovčanin, IT-05-88-AR65.3, ICTY អង្គជំនុំជម្រះឧទ្ធរណ៍, ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧។

[27] សារណាតបទៅនឹងអៀង ធីរិទ្ធកថាខណ្ឌ១០-១១។

*សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចអង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់។*

របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងមធ្យោបាយធនធានរបស់ជនជាប់ចោទ។ ដោយហេតុថា សហចៅក្រមស៊ើបអង្កេត យល់ឃើញថា ពុំមានការប្រែប្រួលស្ថានការណ៍ ទើបដីកានេះពុំកែប្រែសំអាងហេតុមុនៗរបស់ខ្លួនដែលផ្អែកលើភស្តុតាងពាក់ព័ន្ធនឹងលទ្ធភាពធនធានរបស់ជនជាប់ចោទ និងការបង្កឱ្យមានហានិភ័យរត់គេចខ្លួន[28]។ ប្រសិនបើ ត្រូវការអ្វីបន្ថែម ដើម្បីគាំទ្រដល់ការអះអាងដែលរងការជំទាស់នេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល បន្ថែមនូវឯកសារយោងនៅក្នុងដីកាកន្លងមករបស់សហចៅក្រមស៊ើបអង្កេត[29]។

### ២.១.៣ ការឆ្លើយតបរបស់ អៀង ធីរិទ្ធ ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា

១៤. ក្នុងការឆ្លើយតបរបស់ខ្លួន អៀង ធីរិទ្ធ លើកឡើងថា សារណាបណ្តឹងសាទុក្ខរបស់ខ្លួន គឺឈរលើមូលដ្ឋាននៃកំហុសឆ្គងអង្គហេតុ និងកំហុសឆ្គងអង្គច្បាប់ ហើយដោយអនុលោមទៅតាមវិធាន ១០៤ និង១០៥នៃវិធានផ្ទៃក្នុង កំហុសឆ្គងនេះ គឺជាទឡ្ហីករណ៍ស្វ័យតដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[30]។ ជនជាប់ចោទ ក៏បានលើកឡើងផងដែរថា ការរក្សាទុកក្នុងឃុំខុសច្បាប់ តែងតែបង្កឱ្យមានការខូចខាតទោះបីជាវាមិនមែនជាលក្ខណៈប្រាក់កាសក៏ដោយ[31]។

## ២.២ សារណានៃបណ្តឹងសាទុក្ខរបស់ នួន ជា

### ២.២.១ ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ នួន ជា

១៥. នួន ជា ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបីចំណុចជាសំខាន់ដូចខាងក្រោម៖

[28] សារណាតបទៅនឹង អៀង ធីរិទ្ធ កថាខណ្ឌ១៣-១៥ យោងលើឯកសារC20/8, កថាខណ្ឌ២៣-២៤ និងយោងលើឯកសារ C20 កថាខណ្ឌ៨ និង C20/4 កថាខណ្ឌ២៨។

[29] សារណាតបទៅនឹងអៀង ធីរិទ្ធកថាខណ្ឌ១៦។

[30] ការឆ្លើយតបរបស់អៀង ធីរិទ្ធ កថាខណ្ឌ២។

[31] ការឆ្លើយតបរបស់អៀង ធីរិទ្ធ កថាខណ្ឌ៣-៥។

ក. អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ក្នុងការបកស្រាយ និងអនុវត្ត វិធាន៦៨នៃវិធានផ្ទៃក្នុង

ខ. អង្គជំនុំជម្រះសាលាដំបូង មិនបានអើពើគោលការណ៍*ដំណោះស្រាយស្ពាន (Ultimum Remedium)* និង

គ. ការដោះលែងជាបន្ទាន់ គឺជាដំណោះស្រាយតែមួយគត់ដែលមានលក្ខណៈសមស្រប។

១៦. នួន ជា ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល៖

ក. ចាត់ទុកសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជាមោឃៈ

ខ. ធ្វើការបង្គាប់ឱ្យដោះលែង នួន ជា ជាបន្ទាន់ (ឬ កែប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យមានលទ្ធផលដូចគ្នានេះ) និង

គ. បើកសវនាការស្ដីពីបណ្ដឹងសាទុក្ខឱ្យបានឆាប់ដែលអាចធ្វើទៅបាន[32]។

### ២.២.១.១ អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ក្នុងការបកស្រាយ និងអនុវត្តវិធាន៦៨នៃវិធានផ្ទៃក្នុង

១៧. នួន ជា ជំទាស់ថា ពាក់ព័ន្ធទៅនឹងការធ្វើឱ្យមានតុល្យភាពនៃផលប្រយោជន៍ អង្គជំនុំជម្រះសាលាដំបូង មិនគោរពតាមអត្ថន័យនៃវិធាន៦៨នៃវិធានផ្ទៃក្នុង ដែលចែងអំពីការដោះលែងជាបន្ទាន់ថាជាសំណងតែមួយគត់[33]។ ពីព្រោះតែពុំមានសេចក្ដីសម្រេចដែលមានសំអាងហេតុណាមួយត្រូវបានចេញក្នុងរយៈពេលបួនខែចាប់ពីពេលចេញដីកាដំណោះស្រាយ វាមានន័យថា ពុំមានសេចក្ដីសម្រេចណាមួយត្រូវបានចេញដោយស្របទៅនឹងវិធាន៦៨នៃវិធានផ្ទៃក្នុងឡើយ។ ដូចនេះ នៅក្នុងដីកាដំណោះស្រាយ លែងមានអានុភាពតទៅទៀត ហើយ នួន ជា គប្បីត្រូវបានដោះលែង[34]។

---

[32] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ៣៧។

[33] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ១៤-១៥។

[34] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ១៦-១៧។

00702287



នួនជា លើកឡើងថា ពាក្យនៅក្នុងវិធាន៦៨នៃវិធានផ្ទៃក្នុង មានលក្ខណៈច្បាស់លាស់ណាស់ ហើយកិច្ចប្រជុំពេញអង្គ បានអនុម័តលើពាក្យជំនួស ឧទាហរណ៍ដូចជា សេចក្តីសម្រេចត្រូវចេញក្នុងរយៈពេលបួនខែដោយមានសំអាងហេតុ តាមក្រោយ "តាមពេលវេលាសមស្រប"[35]។

### ២.២.១.២ អង្គជំនុំជម្រះសាលាដំបូង មិនគោរពគោលការណ៍ដំណោះស្រាយស្ពាន (Ultimum Remedium)

១៨. នួន ជា លើកឡើងថា អង្គជំនុំជម្រះសាលាដំបូង បានគាំទ្រការពុំអើពើរបស់អង្គបុរេជំនុំជម្រះទៅលើគោលការណ៍ដំណោះស្រាយស្ពាន ដែលថា អង្គបុរេជំនុំជម្រះ មានចេតនាចេញសេចក្តីសម្រេចរបស់ខ្លួនដោយគ្មានសំអាងហេតុ ទោះបីបានដឹងអំពីលក្ខខណ្ឌតម្រូវឱ្យផ្តល់សំអាងហេតុក៏ដោយ[36]។ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចដោយគ្មានសំអាងហេតុ ក្នុងគោលបំណងតែមួយគត់ដើម្បីបញ្ចៀសការដោះលែង នួន ជា ដោយស្វ័យប្រវត្តិ ពីព្រោះពុំមានលក្ខខណ្ឌតម្រូវគតិយុត្តណាមួយដែលអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ ចេញនូវសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នោះឡើយ តាមពិត ជាពេលវេលាផុតកំណត់ ដែលអង្គបុរេជំនុំជម្រះបានកំណត់ដោយខ្លួនឯង[37]។

១៩. នួន ជា លើកឡើងថា ប្រសិនបើអង្គបុរេជំនុំជម្រះ បានវាយតម្លៃម៉ត់ចត់ត្រឹមត្រូវរាល់បញ្ហាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ដោយមានការផ្តល់នូវសំអាងហេតុគ្រប់គ្រាន់នោះ វាមាន លក្ខណៈច្បាស់លាស់ថា សេចក្តីសម្រេចនេះអាចចេញក្រោយពេលកំណត់ក្នុងរយៈពេលបួនខែ។ ការពិតដែលថា អង្គបុរេជំនុំជម្រះ បានជូនដំណឹងនូវលទ្ធផលនៃការពិភាក្សាសម្រេចរបស់ខ្លួន(គឺថា បដិសេធនូវបណ្តឹងឧទ្ធរណ៍)នោះ វាអាចបង្ហាញដល់អ្នកសង្កេតការណ៍ខាងក្រៅប្រកបដោយសុភវិនិច្ឆ័យនូវការចាប់អារម្មណ៍មួយថា លទ្ធផលនេះ មានការគិតទុកជាមុន និងថា អង្គបុរេជំនុំជម្រះ យល់ឃើញដោយខ្លួនឯងជាមួយនឹងការគាំទ្រលទ្ធផលដែល

---

[35] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ១៩ ជើងទំព័រ៤២។

[36] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ២២។

[37] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ២៣ និង២៦។

គិតទុកជាមុននេះតាមរយៈទម្លាប់ករណ៍នានា ដែលនេះមានការកែប្រែ លំដាប់លំដោយនៃសំអាងផ្នែកច្បាប់ដែលតម្រូវ[38]។

### ២.២.១.៣ ការដោះលែងជាបន្ទាន់ គឺជាសំណងតែមួយគត់ដែលមានលក្ខណៈសមស្រប

២០. នៅពេលដែលអះអាងថា វិធាន៦៨នៃវិធានផ្ទៃក្នុងមិនមានចែងអំពីតុល្យភាពនៃផលប្រយោជន៍ ប៉ុន្តែ ផ្ទុយទៅវិញ វិធាននេះអនុញ្ញាតឲ្យមានការដោះលែងដោយស្វ័យប្រវត្តិ នួន ជា លើកឡើងថា ប្រសិនបើមានការពិចារណាអំពីការរក្សាតុល្យភាពនៃផលប្រយោជន៍ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង គប្បីពិចារណាលើលក្ខណៈពិសេសនៃព្យសនកម្មជាក់ស្តែងដែលអង្គបុរេជំនុំជម្រះជាប់ពាក់ព័ន្ធនឹងទង្វើដែលគេអាចចាត់ទុកថាជាអំពើអយុត្តិធម៌ និងបានរំលោភបំពានដោយចេតនានូវវិធានផ្ទៃក្នុងដែលសម្រាប់ការពារ នួន ជា ផ្ទាល់[39]។ ទាំងនេះ គប្បីគេធ្វើសេចក្តីសន្និដ្ឋានមួយថា ការដោះលែងជាបន្ទាន់ គឺជាសំណងតែមួយគត់ដែលអាចអនុវត្តបាន។

២១. នួន ជា លើកឡើងថា វិធាន៦៨នៃវិធានផ្ទៃក្នុង គឺជាបញ្ញត្តិដែលចែងអំពីបញ្ហាជាក់លាក់ដែលគួរយកមកអនុវត្ត នៅពេលពិចារណាអំពីអានុភាពនៃដីកាដំណោះស្រាយ និងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយស្តីពីការឃុំខ្លួនបណ្តោះអាសន្ន។ វិធាន៦៨នៃវិធានផ្ទៃក្នុងខុសប្លែកពីបទប្បញ្ញត្តិទូទៅស្តីពីការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងក្នុងវិធាន៦៣នៃវិធានផ្ទៃក្នុង។ ដូច្នេះ មានតែវិធាន៦៨នៃវិធានផ្ទៃក្នុងតែមួយគត់ ដែលអនុវត្តបាន ហើយសំណងតែមួយគត់ដែលវិធានផ្ទៃក្នុងនេះទទួលស្គាល់នោះ គឺការដោះលែងជាបន្ទាន់[40]។

### ២.២.២ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង នួន ជា

២២. សហព្រះរាជអាជ្ញា ធ្វើការឆ្លើយតបទៅនឹងសារណារបស់ នួន ជា នូវមូលដ្ឋានចំនួនបីចំណុច:

---

[38] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ២៨ (ជើងទំព័រ៥១)។

[39] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ៣១-៣៣។

[40] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ៣៤។



SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

ក. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងលើដំណោះស្រាយនានា មានភាពសមស្រប និងស្ថិតក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់ខ្លួន

ខ. អង្គជំនុំជម្រះសាលាដំបូង មិនមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តន៍សិទ្ធិអំណាចឯករាជ្យរបស់ខ្លួន ដើម្បីរក្សាទុក នួន ជា ក្នុងឃុំ និង

គ. នួន ជា ខកខានមិនបានពន្យល់ថាផលប្រយោជន៍របស់ខ្លួនបានរងផលប៉ះពាល់បែបណាខ្លះ ដោយសារកំហុសដែលខ្លួនបានអះអាងថាមាននៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

### ២.២.២.១ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងលើដំណោះស្រាយនានា មានភាពសមស្រប និងស្ថិតក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់ខ្លួន

២៣. សហព្រះរាជអាជ្ញា លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានដើរតួនាទីនៅក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការយល់ឃើញថា សាលដីការបស់អង្គបុរេជំនុំជម្រះ មិនត្រូវបានទុកជាមោឃៈ ដោយសារកង្វះមូលហេតុភ្លាមៗនោះទេ និងថា អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការពិចារណាអំពីដំណោះស្រាយសមស្របនៅពេលបញ្ចប់សវនាការក្រោយពេលស្តាប់ការសន្និដ្ឋានរបស់ភាគីនានារួច[41]។

### ២.២.២.២ អង្គជំនុំជម្រះសាលាដំបូង មិនមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តន៍សិទ្ធិអំណាចឯករាជ្យរបស់ខ្លួនដើម្បីរក្សាទុក នួន ជា ក្នុងឃុំ

២៤. យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ទឡ្ហីករណ៍របស់ នួន ជា ទាក់ទងនឹងវិធាន៦៨ និង៧៧(១៤) ដែលថា អង្គជំនុំជម្រះសាលាដំបូង ពុំមាននូវមូលដ្ឋានសំអាងផ្លូវច្បាប់គ្រប់គ្រាន់សំរាប់ការរក្សាទុកជនជាប់ចោទក្នុងឃុំ គឺគ្មានហេតុផល ពីព្រោះសេចក្តីសម្រេចរបស់អង្គជំនុំ

[41] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង នួន ជា កថាខណ្ឌ៤-៥។
*សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់។*

SUPREME COURT CHAMBER * CHAMBRE DE LA COUR SUPRÊME * S.C.C * C.S.C *

ជម្រះសាលាដំបូង ត្រូវបានសំអាងលើវិធាន៨២នៃវិធានផ្ទៃក្នុង។ ពុំមានបញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង គាំទ្រអំណះអំណាងដែលថា អត្ថិភាពពីមុននៃកំហុសនីតិវិធីនៅក្នុងសេចក្តីសម្រេចឃុំខ្លួនរបស់អង្គបុរេជំនុំជម្រះ បដិសេធទៅនឹងការរក្សាទុកជនជាប់ចោទក្នុងឃុំ ឬអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្គាប់ឱ្យមានការរក្សាទុកក្នុងឃុំដោយអនុលោមតាមអំណាចឯករាជ្យរបស់ខ្លួននោះទេ[42]។

### ២.២.២.៣ នួន ជា ខកខានមិនបានពន្យល់ថាផលប្រយោជន៍របស់ខ្លួនបានរងផលប៉ះពាល់បែបណាខ្លះ ដោយសារកំហុសដែលខ្លួនបានអះអាងថាមាននៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

២៥. សហព្រះរាជអាជ្ញាលើកឡើងថា វិធាន១០៤ គូសបញ្ជាក់ថា បណ្តឹងសាទុក្ខភ្លាមៗ ត្រូវតែបង្ហាញអំពីកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូង និងផលប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខដែលកើតឡើងដោយសារតែការភាន់ច្រឡំនោះ។ នួន ជា ខកខានមិនបានពន្យល់ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បាននាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។ បញ្ហានៃបណ្តឹងសាទុក្ខនៅទីនេះ គឺមិនមែនជាបញ្ហាអំពីថាតើ អង្គបុរេជំនុំជម្រះ គួរបានធ្វើសកម្មភាពផ្សេងពីនេះវិញ ឬ មួយយ៉ាងណានោះទេ។ ផ្ទុយទៅវិញ សំណួរដែលពាក់ព័ន្ធនោះគឺថាតើអង្គជំនុំជម្រះសាលាដំបូង មានការភ័ន្តច្រឡំនៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងលក្ខណៈដែលធ្វើឱ្យមានការខូចខាតដល់សិទ្ធិ ឬផលប្រយោជន៍របស់ជនជាប់ចោទ នួន ជា ដែរឬទេ?[43]។

### ២.២.៣ ការឆ្លើយតបរបស់ នួន ជា ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា

២៦. នៅក្នុងការឆ្លើយតបរបស់ខ្លួន នួន ជា៖

ក. កត់សំគាល់ថា សារណាតបរបស់សហព្រះរាជអាជ្ញា មិនត្រឹមត្រូវ ដោយហេតុថា សារណាតបនេះ បានសំអាងលើការសន្មតដែលមិនត្រឹមត្រូវថា បណ្តឹង

[42] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង នួន ជា កថាខណ្ឌ៦-៩។

[43] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង នួន ជា កថាខណ្ឌ១០-១៥។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C. ១៦

សាទុក្ខភ្លាមៗ អាចផ្អែកលើតែកំហុសឆ្គងនៃការប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះទេ ចំណែកឯ វិធាន១០៤(១) និង១០៥(២) ចែងច្បាស់លាស់ថា បណ្តឹងសាទុក្ខ អាចផ្អែកលើកំហុសឆ្គងផ្នែកអង្គហេតុ ឬ អង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង។

ខ. លើកឡើងថា ការដោះលែង គឺជា(នៅតែជា) សំណាងតែមួយគត់ដោយអនុលោមតាម វិធាន៦៨នៃវិធានផ្ទៃក្នុង។ និង

គ. ទាមទារថា គោលការណ៍*ដំណោះស្រាយស្អាតៗ* គួរអនុវត្តលើបណ្តឹងសាទុក្ខនាពេលបច្ចុប្បន្ននេះ។

## ៣. បទដ្ឋាននៃការពិនិត្យឡើងវិញចំពោះបណ្តឹងសាទុក្ខភ្លាមៗ

២៧. យោងតាមវិធាន១០៤(១) និង១០៥(២) នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខភ្លាមៗអាចផ្អែកលើទឡ្ហីករណ៍មួយ ឬ ច្រើនដូចខាងក្រោម:

-កំហុសនៃអង្គហេតុ ដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ

-កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈ សាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះ។

-ការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

២៨. ក្នុងការឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញនៃបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់ថា ទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលមានរៀបរាប់ក្នុងវិធាន១០៥(២)នៃវិធានផ្ទៃក្នុង ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗ ត្រូវតែអានដាច់ចេញពីគ្នា។ ហេតុដូច្នេះ ដើម្បីសំអាងលើទឡ្ហីករណ៍ទីមួយ ឬ ទីពីរនៃបណ្តឹងសាទុក្ខ (កំហុសឆ្គងនៃអង្គច្បាប់ ឬអង្គហេតុ) ភាគីបណ្តឹងសាទុក្ខ មិនតម្រូវឲ្យបង្ហាញអំពីការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានផលប៉ះពាល់ធ្ងន់



SUPREME COURT CHAMBER * CHAMBRE DE LA COUR SUPRÊME * S.C.C * C.S.C

ប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនឡើយ។ វិធាន១០៤(១)នៃវិធានផ្ទៃក្នុង"បន្ថែមពីនេះបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំអោយប៉ះពាល់ដល់សិទ្ធិ របស់ម្ចាស់បណ្តឹងសាទុក្ខ"។ ឃ្លានេះ បង្កើតនូវទឡ្ហីករណ៍បន្ថែមមួយសម្រាប់បណ្តឹងសាទុក្ខភ្លាមៗ ដែលទឡ្ហីករណ៍នេះ មិនមែនសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមឡើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វាមិនមែនជាទឡ្ហីករណ៍តែមួយគត់សំរាប់បណ្តឹងសាទុក្ខភ្លាមៗនោះឡើយ។

## ៤. ផ្នែកសំអាងហេតុ

### ៤.១.ការទទួលយកនូវទឡ្ហីករណ៍បណ្តឹងសាទុក្ខទីបីរបស់ អៀង ធីរិទ្ធ

២៩. ទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសឆ្គងផ្នែកអង្គហេតុ ដោយការយល់ខុសពីខ្លឹមសារនៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែ ជនជាប់ចោទ ខកខានមិនបានរៀបរាប់លម្អិតនូវទឡ្ហីករណ៍ក្នុងការបង្ហាញកំហុសនៃអង្គហេតុដែលបណ្តាលឲ្យមានភាពអយុត្តិធម៌ ដូចដែលមានចែងក្នុងវិធាន១០៤(១)(ខ) និង១០៥(២)(គ)នៃវិធានផ្ទៃក្នុង ឡើយ។ បន្ទុកក្នុងការបង្ហាញភស្តុតាងនេះ ពុំបានបង្ហាញឲ្យឃើញច្បាស់លាស់នៅក្នុងការអះអាងរបស់ អៀង ធីរិទ្ធ ដែលថាកំហុសឆ្គងនៃអង្គហេតុ "ជាការបំពានសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌"[44]ឡើយ។ លើសពីនេះទៀត អៀង ធីរិទ្ធ ទទួលស្គាល់ថា ទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខនេះ "គឺជាបញ្ហាមួយដែលមិនជាប់ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃមូលដ្ឋានបណ្តឹងសាទុក្ខទីមួយ និងទីពីរ"[45] ហើយជនជាប់ចោទ មិនបានស្នើសុំឲ្យអង្គជំនុំជម្រះ ដោះលែងខ្លួន[46] និងមិនបានជំទាស់ទៅនឹងមូលដ្ឋានច្បាប់នៃការរក្សាទុកក្នុងឃុំបណ្តោះអាសន្នទេ ។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ដើម្បីឲ្យបណ្តឹងសាទុក្ខអាចទទួលយកបានថាត្រឹមត្រូវតាមទំរង់ច្បាប់ ជាការចាំបាច់ សេចក្តី

---

[44] សារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ កថាខណ្ឌ២៨។

[45] សារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ កថាខណ្ឌ២៦។

[46] សារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ កថាខណ្ឌ២៩។



SUPREME COURT CHAMBER * CHAMBRE DE LA COUR SUPRÊME * C.C.C * C.E.T.C

សម្រេចដែលតវ៉ានោះ យ៉ាងហោចណាស់ ត្រូវមានផលប៉ះពាល់ដល់ប្រយោជន៍ស្របច្បាប់របស់ម្ចាស់បណ្តឹងសាទុក្ខ។ ផ្ទុយទៅវិញ ការស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការកែតម្រូវសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង លើមូលដ្ឋាននៃពាក្យពេចន៍សុទ្ធសាធ មិនត្រូវបានអនុញ្ញាតតាមប្រព័ន្ធនីតិវិធីបណ្តឹងសាទុក្ខរបស់អ.វ.ត.ក ឡើយ។

៣០. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល សម្រេចថា ទឡ្ហីករណ៍ទីបីនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ មិនអាចទទួលយកបានឡើយ។ ហេតុដូច្នេះ នៅក្នុងសេចក្តីសម្រេចនេះ បដិសេធមិនធ្វើការពិចារណាអំពីភាពត្រឹមត្រូវនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងស្ថានភាពនៃធនធានរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា បរិបទសមស្របក្នុងការពិចារណាលើបញ្ហាជាក់ស្តែងនេះ អាស្រ័យនឹងសេចក្តីសម្រេចលើកក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីពាក្យសុំដោះលែងថ្មីមួយទៀត របស់ អៀង ធីរិទ្ធ[47]។

## ៤.២ ការចាប់ផ្តើមនៃកាលបរិច្ឆេទរយៈពេលបួនខែនៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង

៣១. ដើម្បីកំណត់ថាតើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ត្រូវចេញក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង ដែរឬទេនោះ វាចាំបាច់ត្រូវកំណត់អំពីពេលប្រតិបត្តិការចាប់ផ្តើម និងបញ្ចប់។ អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ផ្តល់សំអាងហេតុខុសលើបញ្ហានេះ ហើយនិងផ្តោតទៅលើបញ្ហា ថាតើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលចេញនូវផ្នែកសម្រេចសេចក្តីដោយមិនទាន់មានសំអាងហេតុ និងចេញសំអាងហេតុពេលក្រោយ ជាការបង្កើតឱ្យមានការរំលោភផ្នែកនីតិវិធី ដែលប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូល

---

[47] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ៤២ ("មេធាវីការពារក្តី មិនតម្រូវឱ្យបង្ហាញស្ថានភាពប្រែប្រួល តាមវិធាន៨២(៤) ប្រសិនបើមានសំណើថ្មីសុំដោះលែង ត្រូវបានធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះទេ")។ *សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់។*

សង្កេតឃើញថា បញ្ហានេះនឹងត្រូវ លើកយកមកពិចារណា លុះត្រាណា វាបានបង្ហាញថា សេចក្តីសម្រេចពាក់ព័ន្ធរួមទាំងសំអាងហេតុនៃសេចក្តីសម្រេចនោះផង ត្រូវបានអង្គបុរេជំនុំជម្រះសម្រេច ហួសពេលវេលាកំណត់ដែលត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង។ ដោយផ្អែកតាមការបកស្រាយដ៏ត្រឹមត្រូវនៃវិធានផ្ទៃក្នុង ប្រសិនបើ ផ្នែកសម្រេចសេចក្តី និងសំអាងហេតុ ត្រូវចេញក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនោះ បញ្ហានៃការបំបែកនេះ ពុំមែនជាបញ្ហាចោទឡើយ។ ដូច្នេះ ដំបូង ជាការចាំបាច់ណាស់ ត្រូវសម្រេចថាតើ សំអាងហេតុរបស់អង្គបុរេជំនុំជម្រះសំរាប់សំណុំរឿងក្តីនេះ ត្រូវបានអង្គបុរេជំនុំជម្រះ ចេញក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង ក្នុងរឿងរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នសម្រាប់សេចក្តីសម្រេច របស់ខ្លួនដែរឬទេ។

៣២. ហេតុដូច្នេះ ដើម្បីបដិសេធចោលនូវសំណើចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង គប្បីមានការចាប់ផ្តើមកំណត់នូវការផុតកំណត់នៃកាលបរិច្ឆេទរយៈពេលបួនខែ នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ជាពិសេស ដោយបកស្រាយអំពីភាពខ្វះចន្លោះនៃវិធានផ្ទៃក្នុង ទាក់ទងទៅនឹងចំណុចចាប់ផ្តើមគិតនៃកាលបរិច្ឆេទនេះ។ បញ្ហានេះ ទាមទារឲ្យមានការបកស្រាយច្បាស់លាស់ ដោយហេតុថា មានហេតុផលមួយចំនួនស្ថិតនៅពីក្រោយអង្គបុរេជំនុំជម្រះ ដែលមានលក្ខណៈពិសេសក្នុងការជ្រើសរើស ដោយធ្វើការបំបែករវាងផ្នែកសម្រេចសេចក្តី និងផ្នែកសំអាងហេតុ។ អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា ពេលវេលាកំណត់ជាក់ស្តែង នៅតែជាចំណុចមួយនៃការខ្វែងគំនិតគ្នារវាងជនជាប់ចោទ។ អៀង ធីរិទ្ធ លើកឡើងថា រយៈពេលបួនខែក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ផុតកំណត់"យ៉ាងយូរបំផុត"ត្រឹមថ្ងៃទី២១ ខែមករា ឆ្នាំ២០១១[48]។ ផ្ទុយទៅវិញ នួន ជា បានលើកឡើងថា វិធាន៦៨នៃវិធានផ្ទៃក្នុង គប្បីត្រូវបានបកស្រាយថា រយៈ

[48] សារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធកថាខណ្ឌ៥ និង១៣។ សូមមើលសារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ កថាខណ្ឌ២២ៈ"វិធាន៦៨(២) មានន័យច្បាស់លាស់ថា វិធាននេះ តម្រូវឲ្យអង្គបុរេជំនុំជម្រះសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងរយៈពេល៤ខែចាប់ពីថ្ងៃធ្វើបណ្តឹង។ មេធាវីការពារក្តី ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ [ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០] និងរយៈពេលកំណត់បួនខែ គឺផុតកំណត់នូវថ្ងៃទី២១ [illegible] បន្ទាប់ពីកាលបរិច្ឆេទនោះ និងរហូតដល់សេចក្តីសម្រេចដែលមានសំអាងហេតុរបស់អង្គបុរេជំនុំជ[illegible] ការរក្សាជនជាប់ចោទ ទុកក្នុងឃុំខុសច្បាប់"។ ការកែសម្រួលអង្គជំនុំជម្រះតុលាការកំពូលចំពោះកា[illegible] បណ្តឹង សាទុក្ខរបស់ អៀង ធីរិទ្ធ ត្រូវបានបញ្ជាក់ជាមួយក្រុមមេធាវីរបស់អៀង ធីរិទ្ធនៅថ្ងៃទី១៩ ខែ[illegible]។ *សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចនៃ[illegible] លើសំណើសុំដោះលែងជាបន្ទាន់។*

ពេលកំណត់បួនខែ គឺគិតចាប់ពីពេលចេញដីកាដំណោះស្រាយ[49]។ សហព្រះរាជអាជ្ញា មិនបាន លើកឡើងឲ្យបានជាក់លាក់លើចំណុចនេះទេ។

៣៣. យោងតាមសំអាងហេតុដែលមាននៅក្នុងកថាខណ្ឌខាងក្រោម អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ពេល កំណត់រយៈពេលបួនខែនៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ត្រូវគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹង

ឧទ្ធរណ៍ផ្នែកខ្លឹមសារប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ ការអះអាងនេះ គឺ អនុលោមតាមវិធាន៦៨(១)-(៣) នៃវិធានផ្ទៃក្នុងដែលចែងថា:

១. ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និង ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាលក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ឬ ឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥នៅតែតម្រូវ សហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬ រក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែកនៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង។

២. នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អានុភាពនៃសេចក្តីសម្រេចរក្សាជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តមានអានុភាពអនុវត្តរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ ។អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងអំឡុងពេល៤(បួន)ខែ ។

៣. ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬ រក្សាលក្ខខណ្ឌ នៃការដាក់អោយនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ត្រូវអស់អានុភាពក្នុងរយៈពេល៤(បួន)ខែក្រោយលើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល

[49] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧ ២៨ ៣៦។

*សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចនៃអង្គ*

*លើសំណើសុំដោះលែងជាបន្ទាន់។*

00702296



៣៤. ដោយមិនមានពាក្យពេចន៍ច្បាស់លាស់នៅក្នុងវិធាន ៦៨(២) នៃវិធានផ្ទៃក្នុង ការចាប់ផ្តើមគិតនៃកាលបរិច្ឆេទរយៈពេលកំណត់បួនខែ ត្រូវកំណត់តាមរយៈការវិភាគអំពីបរិបទជាប្រព័ន្ធ និងគោលបំណងនៃការកំណត់ពេលវេលា។ ពាក់ព័ន្ធនឹងខ្លឹមសារនៅក្នុងបរិបទទីមួយនេះ ឧបញ្ញត្តិក្នុងន័យបើកទូលាយ (នៅពេលដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) គឺជាសញ្ញាបង្ហាញដំបូងថា ការចាប់ផ្តើមនៃពេលវេលាកំណត់នៅក្នុងកថាខណ្ឌនេះ គឺគិតពីពេលដាក់បណ្តឹងឧទ្ធរណ៍ ប៉ុន្តែ មិនគិតពីពេលចេញដីកាដំណោះស្រាយឡើយ។ ហេតុដូច្នេះ ចំណុចចាប់ផ្តើមសម្រាប់រយៈពេលកំណត់នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មិនអាចគិតនៅពេលដែលចេញដីកាដំណោះស្រាយដែលជាព្រឹត្តិការណ៍មួយដែលកើតមុនពេលធ្វើបណ្តឹងឧទ្ធរណ៍។ ទាក់ទងទៅនឹងគោលបំណងនៃរយៈពេលកំណត់បួនខែនៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង គឺដើម្បីរារាំងការរក្សាទុកជនជាប់ចោទក្នុងឃុំហួសពេលកំណត់។ ហេតុដូច្នេះ នៅពេលដែលអង្គបុរេជំនុំជម្រះ សម្រេចរក្សាទុកជនជាប់ចោទក្នុងឃុំ អង្គបុរេជំនុំជម្រះ ត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេលកំណត់នេះ។ ដូចគ្នាដែរ ពេលកំណត់នេះ មានគោលបំណងដើម្បីផ្តល់ឱ្យអង្គបុរេជំនុំជម្រះនូវពេលវេលាគ្រប់គ្រាន់សំរាប់ពិនិត្យលើសំណុំរឿង និងបញ្ចប់នូវ សេចក្តីសម្រេចរបស់ខ្លួន។ វាមិនមានលក្ខណៈសមហេតុផលក្នុងការបកស្រាយថា "រយៈពេលបួន ខែ" ក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ត្រូវរាប់បញ្ចូលផងដែរនូវរយៈពេលដែលអង្គបុរេជំនុំជម្រះ មិនអាចធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ដែលមិនស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ដូចជាកង្វះការដឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍ ឬ កង្វះការដឹងអំពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍។

៣៥. មាននីតិវិធី និងទំរង់បែបបទនានាដែលមានចែងក្នុងវិធានផ្ទៃក្នុងបានកំណត់លក្ខខណ្ឌចំពោះលទ្ធភាពរបស់អង្គបុរេជំនុំជម្រះ ក្នុងការចាប់ផ្តើមកិច្ចការរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខប្រកបដោយប្រសិទ្ធភាព។ វិធាន៧៧(២)នៃវិធានផ្ទៃក្នុងចែងថា បន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿង ឬ ឯកសារចម្លង ទៅឱ្យអង្គបុរេជំនុំជម្រះ ក្នុងរយៈពេលប្រាំថ្ងៃ។ វិធាន៧៥(១)និង(៣)នៃវិធានផ្ទៃក្នុងចែងថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មានរយៈពេលដប់ថ្ងៃដើម្បីដាក់សេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍ និង៣០ថ្ងៃ ដើម្បីដាក់សារណានៃបណ្តឹងឧទ្ធរណ៍គិតចាប់ពីថ្ងៃទទួលបាននូវការជូនដំណឹងនៃសេចក្តីសម្រេច ឬ ដីកាដែលអាចតវ៉ាបាន។ ដោយស្របតាមហេតុផលដូចគ្នានេះ ការកំណត់

ពេលវេលា ដូចដែលមានចែងខាងលើ វាមិនសមហេតុផលទេក្នុងការចងភ្ជាប់នូវការចាប់ផ្តើមគិតនៃរយៈពេល“៤ខែ”នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ទៅនឹងថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ភាគីនោះឡើយ។ វាខុសប្លែកពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[50] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ គឺគ្រាន់តែជាការបង្ហាញឱ្យឃើញពីចេតនារបស់ភាគីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេច ឬ ដីការបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ[51]។ ផ្ទុយទៅវិញ សារណាបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ “ ត្រូវមានសំអាងហេតុ ផ្នែកអង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋានបណ្តឹងឧទ្ធរណ៍ រួមទាំងឯកសារគាំទ្រទាំងអស់”[52]។ ហេតុដូច្នេះ បន្ទាប់ពីទទួលបាននូវសារណាបណ្តឹងឧទ្ធរណ៍ពីភាគី និងសំណុំរឿងពីសហចៅក្រមស៊ើបអង្កេត ទើបអង្គបុរេជំនុំជម្រះអាចកំណត់ពីវិសាលភាពនៃការពិនិត្យដែលខ្លួនត្រូវធ្វើលើបណ្តឹងឧទ្ធរណ៍នេះ។

៣៦. ហេតុផលដូចគ្នា សំរាប់ការគណនានៃពេលកំណត់ បានបង្ហាញពីភាពចាំបាច់ក្នុងការធានាបាននូវពេលវេលាសមហេតុផល សំរាប់ភាគីធ្វើសកម្មភាពបណ្តឹង ដោយពុំមានផលប៉ះពាល់ដល់ពេលវេលាដែលបានផ្តល់ឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចឡើយ។ ភាគី ត្រូវដាក់សារណាបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេច ឬ ដីកាដែលអាចតវ៉ាបាន។ នៅក្នុងករណីដែលម្ចាស់បណ្តឹងឧទ្ធរណ៍ដាក់សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទីមួយក្នុងរយៈពេលដប់ថ្ងៃតាមវិធាន៧៥(១)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ អាចរង់ចាំរហូតដល់២៩ថ្ងៃទៀតសំរាប់ទទួលយក “សំអាងហេតុផ្នែកអង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍”។ អង្គបុរេជំនុំជម្រះ អាចនឹងរង់ចាំយូរជាងនេះទៅទៀត ប្រសិនបើអង្គបុរេជំនុំជម្រះអនុញ្ញាតការពន្យាពេលដាក់សារណាបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើកាលៈទេសៈពិសេស។ បញ្ញត្តិដ៏ទៃទៀតនៅក្នុងវិធានផ្ទៃក្នុងគាំទ្រការបកស្រាយដែលថា ការចាប់ផ្តើមនៃកាលបរិច្ឆេទសំរាប់រយៈ

---

[50] វិធាន១០៥(៣)នៃវិធានផ្ទៃក្នុង។

[51] វិធាន៧៥នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល រំលឹកថា កិច្ចប្រជុំពេញអង្គ បានណែនាំជាពិសេស[illegible] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលត្រូវដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយមានទស្សនៈទាន[illegible] អង្គជំនុំជម្រះក្នុងកម្ពុជា។

[52] វិធាន៧៥(៣)-(៤)។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME *C.C.C*C.*

ពេល"បួនខែ"ក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មិនអាចចាប់ផ្តើមគិតនៅពេលណាមួយមុនពេលដាក់សារណាលើបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឡើយ។ ជាពិសេស រយៈពេលបីខែដែលអង្គជំនុំជម្រះតុលាការកំពូល ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗស្តីពីការឃុំខ្លួន ត្រូវគិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខ[53]។

៣៧. អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ថា ការយល់ឃើញរបស់ខ្លួនអំពីការចាប់ផ្តើមគិតរយៈពេលកំណត់ ដូចមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មិនដូចគ្នាទៅនឹងបញ្ញត្តិពាក់ព័ន្ធនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡើយ ហេតុដូច្នេះ សំអាងរបស់ជនជាប់ចោទដែលផ្អែកលើមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[54] មិនមានន័យឡើយ។ ទោះបីជារយៈពេល "បួនខែ"មានចែងក្នុងមាត្រា២៤៩[55]នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវគិតចាប់ពីពេលចេញដីកាដំណោះស្រាយក៏ដោយ ក៏ភាពពាក់ព័ន្ធនៃបទប្បញ្ញត្តិនេះ ក៏ដូចជាបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដទៃទៀតដែលគ្រប់គ្រងលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[56] ត្រូវតែមានការវាយតម្លៃលើគ្រប់ទិដ្ឋភាពដែលមានចែងក្នុងក្រមនេះ ។ ក្នុងន័យនេះ ភាពខុសគ្នាជាសារវន្តត្រូវតែយកមកពិចារណារវាងគោលបំណង នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុងចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលឆ្លុះបញ្ចាំងឲ្យឃើញពីលក្ខណៈពិសេសនៃ

---

[53] សូមមើលការពន្យល់ក្នុងជើងទំព័រ១៦ខាងលើ។

[54] សូមមើលសារណាបណ្តឹងសាទុក្ខរបស់នួនជា កថាខណ្ឌ១០។ សារណាបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ កថាខណ្ឌ៩។

[55] មាត្រា ២៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។ មាត្រា២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្ត។

ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទ ឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា២០៥ (សំអាងហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)នៃក្រមនេះ។

សេចក្តីសម្រេចរក្សាជនត្រូវចោទក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន មានសុពលភាពក្នុងរយៈពេល៤ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេលបួនខែនេះទេនោះ ជនត្រូវចោទ ត្រូវបានដោះលែងពីការឃុំបណ្តោះអាសន្នឯកឯង។

[56] សូមមើលមាត្រា២៦៦-២៦៨

*សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់។*

អ.វ.ត.ក ដោយមូលហេតុភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងភាពស្មុគស្មាញនៃការស៊ើបអង្កេត តម្រូវការនៃការពិនិត្យពិច័យឱ្យបានម៉ត់ចត់នៅដំណាក់កាលបុរេជំនុំជម្រះលើបទចោទនានា និងតម្រូវការផ្តល់ជំនួយយ៉ាងទំលំទូលាយសំរាប់ជនជាប់ចោទ។ ដូច្នេះ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានប្រមើលមើលពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយដោយជនជាប់ចោទ ក្នុងន័យទូលាយដូចដែលវិធានផ្ទៃក្នុងកំណត់នោះទេ ។ នៅក្នុងវិធានផ្ទៃក្នុង ឧបាស្រ័យប្រឆាំងនឹងដីកាដំណោះស្រាយដោយជនជាប់ចោទ អាចត្រូវបានធ្វើឡើងដោយឯករាជ្យ ដោយផ្អែកលើមូលដ្ឋានយុត្តាធិការ និង/ឬផ្អែកលើមូលដ្ឋានដែលពាក់ព័ន្ធនឹងការរក្សាទុកក្នុងឃុំបណ្តោះអាសន្ន[57]។ ជាងនេះទៅទៀត យោងតាមការផ្តល់សិទ្ធិអំណាចក្នុងន័យចង្អៀត សំរាប់ធ្វើបណ្តឹងឧទ្ធរណ៍ រយៈពេលកំណត់សំរាប់កិច្ចការបណ្តឹងឧទ្ធរណ៍ ដែលចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មានរយៈពេលខ្លីជាងសំរាប់ភាគី ពោលគឺមានរយៈពេលប្រាំថ្ងៃប៉ុណ្ណោះ[58]។ ប៉ុន្តែ រយៈពេលកំណត់សំរាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ យោងតាមបទបញ្ជាផ្ទៃក្នុង ត្រូវបានពន្យារបន្ថែមដោយមូលហេតុមានភាពស្មុគស្មាញដែលបានប៉ាន់ប្រមាណទុកនៃរឿងក្តីនៅចំពោះមុខអ.វ.ត.ក។ ទីបញ្ចប់ បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ទាមទារឱ្យមានការពិនិត្យជាថ្មីឡើងវិញ ខណៈដែលវិធានផ្ទៃក្នុងតម្រូវឱ្យបណ្តឹងឧទ្ធរណ៍ផ្តោតទៅលើការលើកបង្ហាញទម្លឹករណ៍អង្គហេតុ និងអង្គច្បាប់។ សរុបមក ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់នូវសេចក្តីណែនាំចំពោះបញ្ហានៅចំពោះមុខទេ ហើយដែលបទប្បញ្ញត្តិដែលពាក់ព័ន្ធទាំងនោះ មិនមានលក្ខណៈគ្រប់គ្រាន់សំរាប់បណ្តឹងឧទ្ធរណ៍ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំរាប់ឧក្រិដ្ឋកម្មអន្តរជាតិឡើយ។ ការគណនារយៈពេលកំណត់នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ដែលត្រូវផ្តើមគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងឧទ្ធរណ៍ផ្អែកប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវយោងតាមលទ្ធផលសមស្របដែលកើតចេញពីការទទួលយកនូវការរៀបចំជាពិសេសផ្សេងទៀតរបស់អ.វ.ត.ក នៅក្នុងវិធានផ្ទៃក្នុង។

---

[57] វិធាន៧៤(៣)(ក)និង(ច)នៃវិធានផ្ទៃក្នុង។ សូមមើលសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, D427/2/15 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ៥៧-៦៨។

[58] មាត្រា២៧០។ ក្នុងករណីលើកលែង អគ្គព្រះរាជអាជ្ញាមានតែរយៈពេលមួយខែក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ផ្សេងៗ។ *សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់។*

៣៨. នៅក្នុងរឿងក្ដីបច្ចុប្បន្ន ដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ហើយ អៀង ធីរិទ្ធ និង នួន ជា បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី២០ និង២១ ខែកញ្ញា ឆ្នាំ២០១០ ជាបន្តបន្ទាប់ និងដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល កំណត់ថា យោងតាមស្ថានភាពខាងលើរយៈពេលកំណត់បួនខែដែលចែងក្នុងវិធាន៦៨(២) ត្រូវចាប់ផ្ដើមគិតពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ហើយថ្ងៃចុងក្រោយដែលស្របតាមរយៈពេលកំណត់បួនខែ គឺនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះចេញសំអាងហេតុសំរាប់សេចក្ដីសម្រេចដែលនៅសេសសល់នៅក្នុងផ្នែកសម្រេចសេចក្ដីចុងក្រោយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល កំណត់ថា សេចក្ដីសម្រេចអង្គបុរេជំនុំជម្រះដែលមានផ្នែកសម្រេចសេចក្ដី និងផ្នែកសំអាងហេតុ បានធ្វើក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង។

៣៩. ជនជាប់ចោទ បានសំអាងផងដែរលើវិធាន២១(១)នៃវិធានផ្ទៃក្នុង[59]។ អង្គជំនុំជម្រះតុលាការកំពូល សម្រេចថា ការគណនារយៈពេលកំណត់ដោយផ្ដើមគិតចាប់ពីថ្ងៃដាក់សារណាបណ្ដឹងឧទ្ធរណ៍ មានលក្ខណៈស្របទៅនឹងគោលកាណ៍ដែលមានចែងក្នុងវិធាន២១(១)នៃវិធានផ្ទៃក្នុង ដែលកំណត់ថា វិធានផ្ទៃក្នុង ត្រូវតែបកស្រាយ ជាប្រយោជន៍ដល់ជនជាប់ចោទ។ ដើម្បីបញ្ជាក់អំពីភាពស្របគ្នានេះ ជាបឋមគោលការណ៍ដែលមានចែងក្នុងវិធាន២១(១)នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានការបកស្រាយបែបនេះ។ ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូល សម្រេចថា វិធាន២១(១) នៃវិធានផ្ទៃក្នុង ត្រូវតែអានក្នុងន័យថា ការបកស្រាយវិធានផ្ទៃក្នុង មិនត្រូវឱ្យមានការរំលោភលើប្រយោជន៍ណាមួយរបស់ជនជាប់ចោទ ដែលកើតចេញពីសិទ្ធិសារវន្ត ត្រូវបានធានានៅក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍អន្តរជាតិនានាជាធរមាន មានដូចជា ការសន្មត់ថាគ្មានទោស សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ សិទ្ធិនៅស្ងៀមមិនឆ្លើយតប សិទ្ធិទទួលបានការការពារខ្លួន។ ដូច្នេះ ក្នុងការបង្កើតអត្ថន័យគតិយុត្តនៃវិធានផ្ទៃក្នុង ស្ថាប័នមានសមត្ថកិច្ចបកស្រាយគួរតែធ្វើឱ្យស្របតាមវិធាននៃការបកស្រាយច្បាប់ ដោយពិចារណាលើគោលការណ៍ទូទៅទាំងអស់ក្នុងចំណោមគោលការណ៍ផ្សេងៗ ដែលការពារសិទ្ធិរបស់ជនជាប់ចោទ ហើយ [illegible]

[59] សារណាបណ្ដឹងសាទុក្ខរបស់អៀង ធីរិទ្ធ កថាខណ្ឌ១៨។ សារណាបណ្ដឹងសាទុក្ខ នួន ជា កថាខណ្ឌ [illegible] *សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេច[illegible] លើសំណើសុំដោះលែងជាបន្ទាន់។*

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C. ២៦ C.E.T.C.

ក្រោយ គួរតែវាយតម្លៃនៅក្នុងក្របខណ្ឌនៃសិទ្ធិទាំងនោះ។ គោលបំណងនៃការបកស្រាយចេញពីវិធាន២១(១) មិនមានន័យថា វិធានផ្ទៃក្នុង ត្រូវតែបកស្រាយ ក្នុងន័យផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទដោយស្វ័យប្រវត្តិនៅក្នុងគ្រប់ស្ថានភាពជាក់លាក់ដែលកើតចេញពីការបកស្រាយនៃវិធានវិធានផ្ទៃក្នុងឡើយ។

៤០. ទាក់ទិននឹងការគណនានៃរយៈពេលកំណត់ក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា បញ្ហាចោទ គឺមិនមែនជាបញ្ហាស្តីពីសិទ្ធិសារវន្តរបស់ជនជាប់ចោទនោះទេ។ ប៉ុន្តែ ជាបញ្ហាបច្ចេកទេសនៃការបកស្រាយលក្ខន្តិកៈដែលមិនពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធជាសារវន្តរបស់ជនជាប់ចោទឡើយ។ ដូច្នេះ គឺជាបញ្ហាបច្ចេកទេសមួយដែលតម្រូវឱ្យមានការឆ្លើយតបតាមលក្ខណៈបច្ចេកទេសវិញ ដែលជាលទ្ធផលធ្វើការថ្លឹងថ្លែងផលប្រយោជន៍ផ្សេងៗនៅក្នុងដំណើរនីតិវិធី។ ផលប្រយោជន៍របស់ជនជាប់ចោទ ត្រូវតែមានពេលវេលាគ្រប់គ្រាន់សំរាប់ត្រៀមរៀបចំបណ្តឹងឧទ្ធរណ៍ និងតុលាការក៏ត្រូវមានពេលវេលាគ្រប់គ្រាន់ឱ្យតុលាការដើម្បីធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ដែរ ដូច្នេះ ជាការពង្រឹងនូវការធានាថា បទចោទប្រកាន់នានាដែលមិនមានមូលដ្ឋានគ្រប់គ្រាន់ នឹងមិនត្រូវបានបញ្ជូនទៅជំនុំជម្រះបានឡើយ។ ជម្រើសក្នុងការដាក់បណ្តឹងឧទ្ធរណ៍ និងការប្រើប្រាស់ពេលវេលាកំណត់សំរាប់ជនជាប់ចោទ គឺជាការសម្រេចចិត្តដោយស្វ័យភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ផលប្រយោជន៍នេះ ត្រូវបានបំពេញទោះបីជាមានការពន្យារកិច្ចដំណើការនីតិវិធី ដែលរួមមានសេចក្តីសម្រេចបង្គាប់ឱ្យឃុំខ្លួន ហើយចេះតែដើរទៅមុខផ្ទុយទៅនឹងប្រយោជន៍របស់ភាគីដែលមិនធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលសមស្រប។ ប៉ុន្តែ នៅក្នុងរឿងក្តីនេះ សេចក្តីសម្រេចស្តីអំពីការបកស្រាយអំពីការកំណត់ចំណុចចាប់ផ្តើមនៃកាលបរិច្ឆេទ ទោះមួយខែមុន ឬ មួយខែក្រោយក៏ដោយ ក៏មិនបានកំម្រិត ឬ ធ្វើឱ្យបាត់បង់សិទ្ធិជាសារវន្តរបស់ជនជាប់ចោទឡើយ។

៤១. យោងតាមសំអាងហេតុខាងលើ ការកំណត់លើចំណុចចាប់ផ្តើមនៃពេលវេលាកំណត់ក្នុងវិធាន៦៨(២)ស្តីពីការដាក់សារណាបណ្តឹងឧទ្ធរណ៍ មិនបានរំលោភលើវិធាន២១(១)នៃវិធានផ្ទៃក្នុងឡើយ។

### ៤.៣ ឧត្តិករណ៍ទីមួយនៃបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ - ការខកខានមិនបាន លើកពីឧត្តិករណ៍របស់ដើមបណ្តឹងសាទុក្ខ

៤២. អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មិនបានខកខានក្នុងការសម្រេចលើទឡ្ហីករណ៍សំខាន់របស់ជនជាប់ចោទឡើយ។ នៅក្នុងកថាខណ្ឌ២៣នៃសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងយ៉ាងច្បាស់លាស់ថា "ពិចារណាលើការលើកឡើងនៅក្នុងពាក្យសុំរបស់ អៀង ធីរិទ្ធ ដែលថា សាលដីកាលើដីកាដំណោះស្រាយពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសាលដីកាអនុលោមតាមវិធាន៦៨(២) និង(៣)នៃវិធានផ្ទៃក្នុងដោយសារសាលដីកាទាំងនេះ ពុំមានសំអាងហេតុនោះ"។ បន្ទាប់ពីយល់ឃើញថា ការខកខានរបស់អង្គបុរេជំនុំជម្រះ មិនបានសម្រេចក្នុងរយៈពេលកំណត់បួនខែដែលមានចែងក្នុងវិធាន៦៨(២) នៃវិធានផ្ទៃក្នុងនោះ បង្កើតឱ្យមានវិការៈផ្នែកនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ធ្វើការ"វាយតម្លៃថាតើ វិការៈផ្នែកនីតិវិធីនេះ[ផ្នែកសម្រេចសេចក្តី] ប៉ះពាល់ដល់សុពលភាពនៃសាលដីកាទាំងនេះដែរ ឬ យ៉ាងណា"[60]។ យោងតាម កថាខណ្ឌប្រាំពីរជាបន្តបន្ទាប់(៣០-៣៦) អង្គជំនុំជម្រះសាលាដំបូង បានផ្តល់នូវសំអាងហេតុក្នុងការយល់ឃើញទាំងពីររបស់ខ្លួនថា ផ្នែកសម្រេចសេចក្តីចុងក្រោយ គឺជាសេចក្តីសម្រេចដែលមានសុពលភាព ដោយអនុលោមតាមអត្ថន័យនៃវិធាន៦៨(២)-(៣)[61] និងថា តាមកាលៈទេសៈពិសេសទាំងឡាយនៃករណីនេះ មិនអាចជាមូលហេតុដែលតម្រូវឱ្យមានការដោះលែងជាបន្ទាន់ឡើយ[62]។ អៀង ធីរិទ្ធ អាចមិនយល់ស្របតាមសំអាងហេតុនៃអង្គជំនុំជម្រះសាលាដំបូង ហើយ យល់ដោយហេតុផលថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង មិនបានធ្វើការពិចារណាឱ្យស៊ីជម្រៅលើទិដ្ឋភាពនានានៃអនីត្យានុកូលភាពដោយសន្មតក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបយ៉ាងច្បាស់លាស់ដែលស្របតាមអត្ថន័យនៃមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ចំពោះការជំទាស់សំខាន់របស់ អៀង ធីរិទ្ធ អំពីការដកហូតនូវសេរីភាពរបស់ជន

---

[60] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ២៩។

[61] ការយល់ឃើញដោយច្បាស់លាស់ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ [illegible]

[62] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ៣៥។

ជាប់ចោទដោយគ្មានមូលដ្ឋានត្រឹមត្រូវ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធ ទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ ចោលជាអាសារបង់។

## ៤.៤ ទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ និង ទឡ្ហីករណ៍ទីមួយរបស់ នួន ជា - កំហុសឆ្គងក្នុងការបកស្រាយលើវិធាន៦៨នៃវិធានផ្ទៃក្នុង

៤៣. អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា ទឡ្ហីករណ៍ទាំងនេះ សំអាងលើរយៈពេលកំណត់បួនខែដែលមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ហើយត្រូវផុតកំណត់នៅថ្ងៃទី១៦ ឬ ២១ ខែមករា ឆ្នាំ២០១១ (ដូចដែលលើកឡើងដោយ នួន ជា និង អៀង ធីរិទ្ធ រៀងៗខ្លួន)។ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញថា រយៈពេលបួនខែនោះ ត្រូវផុតកំណត់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ និងយល់ឃើញថា អង្គបុរេជំនុំជម្រះ ក៏បានចេញសំអាងហេតុពេញលេញរបស់ខ្លួនដោយមិនហួសកាលបរិច្ឆេទ នោះទេ។ ហេតុដូច្នេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះ ត្រូវបានបដិសេធចោលជាអសារបង់។

## ៤.៥ ទឡ្ហីករណ៍បណ្តឹងសាទុក្ខទីពីររបស់ នួន ជា - ការមិនគោរពរបស់អង្គជំនុំជម្រះសាលាដំបូងលើគោលការណ៍ *ដំណោះស្រាយស្តាពរ*

៤៤. ដោយហេតុថា អង្គបុរេជំនុំជម្រះ បានចេញសំអាងហេតុពេញលេញរបស់ខ្លួនសំរាប់ផ្នែកសម្រេចសេចក្តីរបស់ខ្លួនក្នុងរយៈពេលកំណត់បួនខែនោះ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ពុំចាំបាច់ពិនិត្យលើទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ នួន ជា ទាក់ទងទៅនឹងគោលការណ៍ *ដំណោះស្រាយស្តាពរ*ឡើយ។ ហេតុដូច្នេះ ទឡ្ហីករណ៍បណ្តឹងសាទុក្ខនេះ ត្រូវបានបដិសេធចោលជាអសារបង់។



អង្គជំនុំជម្រះតុលាការកំពូល * SUPREME COURT CHAMBER * CHAMBRE DE LA COUR SUPRÊME * E.C.C.C * E.T.C

## ៤.៦ ទឡ្ហីករណ៍ទីបីនៃបណ្ដឹងសាទុក្ខរបស់ នួន ជា - ការដោះលែងភ្លាមៗ គឺជាសំណងតែមួយគត់ដែលសមស្រប

៤៥. ជាថ្មីម្ដងទៀត ដោយហេតុថា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គបុរេជំនុំជម្រះចេញសំអាងហេតុពេញលេញសម្រាប់ផ្នែកសម្រេចសេចក្ដីចុងក្រោយក្នុងរយៈពេលកំណត់បួនខែ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូល ពុំចាំបាច់ពិចារណា ថាតើ ការដោះលែងភ្លាមៗនេះ គឺជាសំណងតែមួយគត់ដែលសមស្របនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធទឡ្ហីករណ៍បណ្ដឹងសាទុក្ខជាអសារបង់។

## ៤.៧ គ្មានវិការៈផ្នែកនីតិវិធី ឬ ការបំពានសិទ្ធិរបស់ជនជាប់ចោទ

៤៦. អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា "ការយឺតយ៉ាវរបស់អង្គបុរេជំនុំជម្រះ ក្នុងការផ្ដល់នូវសំអាងហេតុចំពោះដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ គឺជាវិការៈផ្នែកនីតិវិធី ដែលជាបឋមបានប៉ះពាល់ដល់សុវត្ថិភាពគតិយុត្ត និងសច្ចភាពផ្លូវច្បាប់នៃសិទ្ធរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌"[63]។

៤៧. អង្គជំនុំជម្រះតុលាការកំពូល រំលឹកថា ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ គឺជាថ្ងៃផុតកំណត់នៃរយៈពេលបួនខែដែលមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ហើយអង្គបុរេជំនុំជម្រះបានចេញសំអាងហេតុពេញលេញរបស់ខ្លួនសំរាប់រាល់ផ្នែកសម្រេចសេចក្ដីសំរាប់ករណីជនជាប់ចោទទាំងពីរ។ ផ្អែកតាមការបញ្ជាក់ខាងលើ ឃើញថា អង្គបុរេជំនុំជម្រះ បានគោរពតាមកិច្ចនីតិវិធីដូចមានចែងវិធាន៦៨(២) និង៧៧(១៤)នៃវិធានផ្ទៃក្នុង ក្នុងការចេញនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងរយៈពេលកំណត់បួនខែ លើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គបុរេជំនុំជម្រះ មិនបានប្រព្រឹត្តវិការៈផ្នែកនីតិវិធី ក្នុងការចេញសេចក្ដីសម្រេចហួសពេលកំណត់ នោះឡើយ។ ដោយមានហេតុទុកជាអសារបង់នៃធាតុសំខាន់ៗ ដូចនេះ មិនមានមូលដ្ឋានក្នុងការរក្សាទុកនូវសំអាងហេតុរបស់

[63] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ២៩។

អង្គជំនុំជម្រះសាលាដំបូងដែលថា នីតិវិធីក្នុងការចេញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្រប តាមវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ។ នៅក្នុងការវិនិច្ឆ័យ របស់អង្គជំនុំជម្រះតុលាការកំពូល មិនមានការបំពានណាមួយលើសិទ្ធិរបស់ជនជាប់ចោទ តាម វិធានផ្ទៃក្នុង និងមិនមានបញ្ហាការទូទាត់សំណងនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល កែប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយលុបចោលកថាខណ្ឌទីពីរ និងទីបី នៃផ្នែកសម្រេចសេចក្ដីនេះចោល[64]។

## ៥. ផ្នែកសម្រេចសេចក្ដី:

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច:**

**បដិសេធ**បណ្ដឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ និង

**កែប្រែ**សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយអនុលោមតាមកថាខណ្ឌ ៤៧ ខាងលើ។

**រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

---

[64] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទំព័រ១៥០:

"**យល់ឃើញថា** ការពន្យាពេលក្នុងការចេញនូវសេចក្ដីសម្រេចនៃការឃុំខ្លួននៅក្នុងផ្នែកសម្រេចសេចក្ដីរបស់ខ្លួន ស្ដីពីដីកាដំណោះស្រាយ បានបណ្ដាលឲ្យមានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ។

**ប្រកាសថា** លក្ខណៈនៃសំណងដោយសារការរំលោភបំពាននេះ អាចត្រូវបានវាយតំលៃនូវពេលបញ្ចប់នៃសវនាការ បន្ទាប់ពីបានស្ដាប់ភាគីស្ដីពីបញ្ហានេះ"។